# មេរៀនទី ១៦៖ ព្រះយេស៊ូវលាងជើងឲ្យពួកសិស្ស

## យ៉ូហាន ១៣៖១-១៧

**មេរៀនសម្រាប់កុមារ** ( *យូធូបលីង* )៖ https://youtu.be/f-tE45FABpA

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/_7yGvdO7hto

**គោលបំណង៖** ព្រះយេស៊ូវចង់ឲ្យយើងបំរើអ្នកដទៃ

**ខគម្ពីរចងចាំ៖** ១ ពេត្រុស ៤៖១០ក *"គឺដោយខំបំរើគ្នាទៅវិញទៅមក តាមអំណោយទានដែលគ្រប់គ្នាបានទទួលមក ទុកដូចជាអ្នកចែកចាយយ៉ាងល្អ.... "។*

**ចំរៀង** ( *យូធូបលីង* )៖

1. ១. ចូរសរសើរព្រះយេស៊ូវ https://youtu.be/PtAbR7-xroM
2. ២. គឺជាការល្អដែលសរសើរព្រះ https://youtu.be/Z91SULEHfho
3. ៣. ចូរបន្ទាបខ្លួននៅចំពោះព្រះអង្គ https://youtu.be/7WO74xMesGU

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«អ្នកបម្រើ ឬក៏ចៅហ្វាយនាយ»**

**ជម្រើសទី១៖**

សំភារៈដែលត្រូវការ៖ ក្រដាសជាមួយនឹងសញ្ញា "O" ឬ "X" សម្រាប់ឲ្យកុមារគ្រប់ៗគ្នា

១. ពេលដែលកុមារដើរចូលមក សូមឲ្យក្រដាសដែលបានរៀបចំហើយ ដែលមានទាំងសញ្ញា "O" ឬ "X" ទៅពួកគេ។

២. សូមពន្យល់ទៅកុមារដែលកាន់ក្រដាស "O" គឺជាអ្នកបំរើ ហើយកុមារដែលកាន់ក្រដាស "X" ជាចៅហ្វាយនាយ។

៣. សូមឲ្យកុមារដែលជាចៅហ្វាយប្រាប់ទៅអ្នកបំរើពីអ្វីដែលពួកគេត្រូវធ្វើ (សំអាតព្រះវិហារ យកទឹកឲ្យកាន់កាបូបឲ្យ ។ល។)

៤. ៥នាទីក្រោយមក សូមផ្លាស់ប្តូរតួនាទីរបស់កុមារ ដែលកាន់ក្រដាសអក្សរ "O" ជាចៅហ្វាយនាយ ហើយកុមារដែលកាន់ក្រដាសអក្សរ "X" ជាអ្នកបំរើវិញ។

**ជម្រើសទី២៖** ល្បែងកំសាន្ត (ស្តេច ម្ចាស់ក្សត្រី មេទ័ព)

របៀបលេង៖ឲ្យកុមារចាប់ដៃគូ ២ៗនាក់ ម្នាក់ជាអ្នកបម្រើ ម្នាក់ទៀតជាស្តេច,ម្ចាស់ក្សត្រីយ,មេទ័ព (ឲ្យកុមារចូលរួមលែងល្បែងនេះទាំងអស់គ្នា)

ពន្យល់ពីកាយវិការ៖ "ស្តេច" ដាក់ជង្គង់ម្ខាងលើខ្នងដៃគូដែលអង្គុយលត់ជង្គង់នោះ "ម្ចាស់ក្សត្រី" អង្គុយ លើចង្កេះដៃគូនោះ "មេទ័ព" អៀវគ្នា

បញ្ជាក់:សូមឲ្យកុមារធ្វើកាយវិការឲ្យលឿនតាមគ្រូស្រែក(ស្តេច ម្ចាស់ក្សត្រី មេទ័ព)បើគ្រូនិយាយថា "ស្តេច" កុមារដែលជាស្តេចត្រូវធ្វើកាយវិការស្តេច អ្នកបម្រើត្រូវអង្គុយលុតជង្គង់និងច្រត់ដៃទាំងពីរលើឥដ្ឋ បើគ្រូស្រែកថាដូរ កុមារត្រូវដូរតួនាទីគ្នាធ្វើ។ ឧទាហរណ៍៖ ស្តេចត្រូវធ្វើជាអ្នកបម្រើវិញម្តង។បើគូរណាធ្វើ ខុស គូនោះជាអ្នកចាញ់។

## ៤. ការណែនាំមេរៀន

យើងទើបតែលេងល្បែងដែលយើងបានធ្វើជាអ្នកបំរើផង និងចៅហ្វាយនាយផង។ បើសិនអាចជ្រើស-រើសបាន តើអ្នកនឹងចង់ធ្វើជាអ្វី? ជាអ្នកបំរើ ឬជាចៅហ្វាយនាយ? ខ្ញុំគិតថាយើងនឹងរើសយកធ្វើជាចៅហ្វាយនាយ។

សូមសួរកុមារ ស្រមៃមើលបើសិនអ្នកជាស្តេច ឬម្ចាស់ក្សត្រីនៃប្រទេសមួយ តើមានអ្វីខ្លះដែលអ្នកចង់ធ្វើក្នុងនាមអ្នកជាស្តេច ឬម្ចាស់ក្សត្រីនោះ? ត្រូវហើយ, មានរឿងជាច្រើនដែលអ្នកអាចធ្វើបាន ប្រសិនបើអ្នកជាស្តេច ឬក៏ម្ចាស់ក្សត្រី។ អ្នកអាចរស់នៅក្នុងព្រះបរមរាជវាំង។ អ្នកអាចញ៉ាំអ្វីដែលអ្នកចង់ញ៉ាំក៏បាន ហើយធ្វើអ្វីដែលអ្នកចង់ធ្វើក៏បាន។ អ្នកអាចស្លៀកសំលៀកបំពាក់ថ្លៃៗ និងអ្នកអាចទទួលបាននូវប្រដាប់ក្មេងលេង និងឧបករណ៍ហ្គេមជាច្រើនដែលអ្នកចង់បាន។ តើអ្នកនឹងបោះបង់តំណែងជាស្តេច ឬម្ចាស់ក្សត្រីហើយក្លាយទៅជាជនក្រីក្រ អនាថាដែរឬទេ?

យើងទាំងអស់គ្នាដឹងថានរណាជាអ្នកបោះបង់បល្ល័ង្ករបស់គាត់ដើម្បីសង្គ្រោះយើងគ្រប់គ្នា។តើម្នាក់នោះជានរណា? ព្រះយេស៊ូវ! ព្រះយេស៊ូវបានចាកចេញពីនគរឋានសួគ៌ ហើយបានមករស់នៅជាបុរសក្រីក្រម្នាក់ ហេតុអ្វី បានជាព្រះអង្គធ្វើដូច្នេះ? ទ្រង់ធ្វើបែបនេះពីព្រោះព្រះអង្គស្រឡាញ់យើងរាល់គ្នា។ ទ្រង់បានមករកយើង រាល់គ្នាដូចជាអ្នកបំរើដែលស្លូតបូតតែមិនមែនជាចៅហ្វាយដ៏កាចសាហាវនោះទេ។ សូមរៀនពីសាច់រឿង ដែលបង្ហាញពីការបំរើដ៏រាបទាបនិងស្លូតបូតរបស់ទ្រង់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះគម្ពីរបានប្រាប់យើងពីពេលវេលាដែលព្រះយេស៊ូវបានបំរើដល់សិស្សរបស់ទ្រង់ដោយរាបទាប។ នៅក្នុងពេលនោះដោយផ្អែកទៅតាមព្រះគម្ពីរ នៅពេលមាននរណាម្នាក់មកផ្ទះរបស់អ្នក អ្នកបំរើនឹងលាងជើងឲ្យភ្ញៀវ ពីព្រោះផ្លូវនៅជំនាន់នោះពោរពេញដោយធូលីដី។ ពេលដែលព្រះយេស៊ូវ និងពួកសិស្សមកជួបជុំគ្នាដើម្បីបរិភោគអាហារដ៏ពិសេសដែលហៅថាបុណ្យរំលង គ្រប់គ្នាត្រូវតែលាងជើងជាមុនសិន។ ប៉ុន្តែមិន-មានអ្នកបំរើណាមកលាងជើងឲ្យព្រះយេស៊ូវ និងពួកសិស្សនោះទេ។ ព្រះយេស៊ូវអាចប្រាប់សិស្សរបស់ទ្រង់ណាម្នាក់ឲ្យមកលាងជើងឲ្យទ្រង់ ឬឲ្យទៅរកអ្នកបំរើណាម្នាក់ មកលាងជើងឲ្យទ្រង់ក៏បាន។

ប៉ុន្តែព្រះយេស៊ូវបានធ្វើឲ្យសិស្សរបស់ទ្រង់មានការភ្ញាក់ផ្អើល ដោយទ្រង់បានយកកន្សែងមករុំលើសម្លៀក-បំពាក់របស់ទ្រង់ ហើយចាប់ផ្តើមលាងជើងឲ្យសិស្សរបស់ទ្រង់ម្នាក់ម្តងៗ។ ព្រះយេស៊ូវបានធ្វើអ្វីដែលការងាររបស់អ្នកបំរើត្រូវធ្វើ! ពេលដែល ព្រះយេស៊ូវទៅដល់មុខពេត្រុស ពេត្រុសបាននិយាយថា "អូ! អត់ទេព្រះយេស៊ូវ ទូលបង្គំមិនចង់ឲ្យទ្រង់លាងជើងឲ្យទូលបង្គំទេ" ពេត្រុសដឹងថាព្រះយេស៊ូវ ជាអ្នកដែលអស្ចារ្យបំផុតក្នុងចំណោមពួកគេទាំងអស់ ហើយមិនគួរឲ្យទ្រង់មកធ្វើការងារជាអ្នកបំរើឡើយ។ ប៉ុន្តែព្រះ-យេស៊ូវមានបន្ទូលថា នេះជារឿងសំខាន់សំរាប់ទ្រង់។

បន្ទាប់មកព្រះយេស៊ូវបានសួរទៅសិស្សរបស់ទ្រង់ "តើអ្នកយល់ពីអ្វីដែលខ្ញុំបានធ្វើទេ?" ព្រះអង្គបានប្រាប់ពួកគេថា "ខ្ញុំធ្វើនេះដើម្បីបង្ហាញជាគំរូសំរាប់អ្នកឲ្យធ្វើតាមខ្ញុំ។ អ្នកត្រូវតែក្លាយទៅជាអ្នកបំរើ។" នៅពេល ដែលព្រះយេស៊ូវលាងជើងឲ្យពួកសិស្ស ទ្រង់បានបង្រៀនពួកគេថាទ្រង់យាងមកបំរើមនុស្ស ហើយទ្រង់ចង់ ឲ្យពួកគេបំរើគ្នាទៅវិញទៅមក។ ថ្ងៃនេះ ព្រះយេស៊ូវកំពុងមានបន្ទូលប្រាប់យើងទាំងអស់គ្នាឱ្យមានបេះដូង ជាអ្នកបម្រើ

ហើយមានឆន្ទៈក្នុងការបំរើមនុស្សក្នុងជីវិតរបស់អ្នក ដូចជាឪពុកម្តាយ បងប្អូន មិត្តភក្តិ គ្រូបង្រៀន និងអ្នកដទៃជាច្រើនទៀត។ តើអ្នកគិតថាអ្នកអាចមានចិត្តបំរើដូចព្រះយេស៊ូវដែរឬទេ?

## ៦. សំនួរពិភាក្សា

១.តាមរយៈសាច់រឿងនេះ តើអ្នកបំរើត្រូវធ្វើអ្វីខ្លះពេលដែលមានភ្ញៀវមកលេងផ្ទះពួកគេ?
*(លាងជើងឲ្យ ភ្ញៀវ)*
២.តើព្រះយេស៊ូវធ្វើអ្វីខ្លះនៅពេលគ្មានអ្នកបំរើមកលាងជើងឲ្យពួកគេ?
*(ព្រះយេស៊ូវបានលាងជើងឲ្យសិស្ស របស់ទ្រង់)*
៣. តើព្រះយេស៊ូវព្យាយាមបង្ហាញអ្វីដល់សិស្សរបស់ទ្រង់ដោយទ្រង់បានលាងជើងដូចជាអ្នកបំរើ?
*( ពួក សិស្សត្រូវមានចិត្តជាអ្នកបំរើ)*
៤. តើអ្នកអាចបំរើអ្នកដទៃនៅក្នុងជីវិតរបស់អ្នកដោយរបៀបណា?
*(លាងចាន ជួយបងប្អូនបង្កើត ជួយ មិត្តភក្តិ)*

## ៧. ខគម្ពីរចងចាំ

១ ពេត្រុស ៤៖១០ *“គឺដោយខំបំរើគ្នាទៅវិញទៅមក តាមអំណោយទានដែលគ្រប់ គ្នាបានទទួល មក ទុកដូចជាអ្នកចែកចាយយ៉ាងល្អ.... ”។*

## ៨. ហាត្ថកម្ម “អរគុណគ្រូគង្វាល!”

**សំភារៈដែលត្រូវការ៖** ឈើដោតការ៉េម ក្រដាស់ពណ៌ កន្ត្រៃ ជ័រកាវ ប៊ិច




១. វិធីមួយនៃការបំរើនោះគឺការអរគុណដល់មនុស្សដែលបានបម្រើអ្នក។ ហើយម្នាក់ដែលបំរើយើងដោយចេញពីចិត្តនោះគឺ គ្រូគង្វាល។ ថ្ងៃនេះ យើងនឹងធ្វើជាផ្កាហើយបិតនៅលើដងការ៉េមកីដើម្បីជូនដល់ គ្រូគង្វាល របស់យើង។

២. ឲ្យក្រដាស់ពណ៌ទៅកុមារគ្រប់គ្នា សំរាប់កុមារតូចៗ ពួកគេអាចយក បាតដៃរបស់ពួកគេដាក់លើក្រដាស គូសតាមគម្រូដៃរបស់គេ រួចកាត់តាមដានដៃនោះ បន្ទាប់មកយកវា មកបិតនៅលើដងការ៉េម។ សំរាប់ក្មេង ធំៗពួកគេអាចកាត់ជារូបផ្កា ហើយបិតវានៅលើដងការ៉េម។



៣. ពេលដែលក្មេងៗជូនផ្កាទៅគ្រូគង្វាល ពួកគេអាចប្រាប់គ្រូគង្វាលថា “អរគុណ លោកគ្រូ/ អ្នកគ្រូដែល បានធ្វើជាគ្រូគង្វាលរបស់យើង” ។

៤. បើសិនអ្នកមានពេលវេលាថែមទៀត ពួកគេគួរតែធ្វើផ្កាទាំងនោះសំរាប់ជាការ អរគុណដល់ឪពុកម្តាយ របស់ពួកគេផងដែរ។

## ៩. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១០. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ពន្ធកិច្ចទាំងមូលរបស់ព្រះយេស៊ូវគឺជាការបន្ទាបខ្លួន។ ស្រមៃថាស្តេចមួយអង្គចាកចេញពីវាំងទៅរស់នៅ ជាបុរសអនាថាក្រីក្រ។ តើមានអ្នកណានឹងធ្វើបែបនេះបានដែរឬទេ? ទេ! ប៉ុន្តែ ព្រះយេស៊ូវបានចាក ចេញពីនគររបស់ទ្រង់នៅស្ថានសួគ៌ ហើយមកផែនដីនេះ ដោយសារទ្រង់ស្រឡាញ់អ្នក។ សូមអរ-ព្រះគុណព្រះយេស៊ូវដែលបានសង្គ្រោះយើង ដើម្បីឲ្យយើងអាចរស់នៅក្នុងនគររបស់ព្រះអង្គ នៅថ្ងៃណាមួយ។ ដោយសារយើងមានព្រះយេស៊ូវ យើងមិនត្រូវខ្មាស់ក្នុងការជួបព្រះឡើយ។ ទ្រង់បាន បន្ទាបខ្លួនចុះដល់ចំណុច មួយដែលទ្រង់សុគតលើឈើឆ្កាងសម្រាប់យើង ដូច្នេះទ្រង់លើក យើងឡើង

ឲ្យខ្ពស់ហើយចូលទៅក្នុង នគររបស់ទ្រង់។ នៅពេលអ្នកបង្រៀនមេរៀននេះ សូមបង្ហាញ ស្មារតីនៃការបន្ទាបខ្លួនទៅចំពោះ កូនសិស្សរបស់អ្នក ។